របាយការណ៍ប្រចាំខែមករា ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ

## I.ស្ថានភាពមន្ទីរ

### ១-ការងាររដ្ឋបាល បុគ្គលិក

មន្ត្រីសរុបចំនួន ៥២ រូប ស្ត្រីចំនួន ០៤ រូប÷ មន្ត្រីទំនេរគ្មានបៀវត្សរ៍ ០០ រូប មន្ត្រីមរណភាព ០០ រូប ប្រធានមន្ទីរ ០១ រូប អនុប្រធានមន្ទីរ ០២ រូប មន្ត្រីក្របខ័ណ្ឌថ្មី ២ រូប (ប្រុស)។

-បានទទួលលិខិតចូលតាមអង្គភាពចំនួន ២៤ លិខិត និង លិខិតចូលពីក្រសួងចំនួន ០៨ លិខិត

-លិខិតចេញទៅអង្គភាពនានាចំនួន ០៣ លិខិត

-លិខិតចេញទៅសាលាខេត្តចំនួន ០១ លិខិត

-លិខិតចេញទៅអង្គភាពមន្ទីរនានាចំនួន ០៥ លិខិត

-លិខិតចេញថវិកាបុរេប្រទាន បៀវត្សរ៍ប្រចាំខែចំនួន ០២ លិខិត

-លិខិតចេញ ឧទ្ទេសនាមមន្ត្រីរាជការចំនួន ០៧ លិខិត

-លិខិតចេញទៅអង្គភាពចំណុះមន្ទីរចំនួន ០៤ លិខិត

-លិខិតអនុញ្ញាតច្បាប់ជូនមន្ត្រីចំនួន ០១ លិខិត

-លិខិតចេញ (របាយការណ៍មន្ទីរ) ចំនួន ០១ លិខិត

### ២-ការងារគណនេយ្យ និង ហិរញ្ញវត្ថុ

| ជំពូក | បរិយាយ | ស្ថានភាពឥណ ទាន គិតជារៀល | បណ្តាខែមុន | ចំណាយក្នុងខែ 01 | ចំណាយ បូក យោង | សមតុល្យ |
|---|---|---|---|---|---|---|
| ៦០ | ការទិញ | 154,700,000 | 0 | 0 | 0 | 154,700,000 |
| ៦១ | សេវាខាងក្រៅ | 426,600,000 | 0 | 0 | 0 | 426,600,000 |
| ៦៣ | ពន្ធ និងអាករ | 3,000,000 | 0 | 0 | 0 | 3,000,000 |
| ៦៤ | បន្ទុកបុគ្គលិក | 412,600,000 | 0 | 30,671,060 | 30,671,060 | 381,928,940 |
| សរុបរួម | | 996,900,000 | 0 | 30,671,060 | 30,671,060 | 966,228,940 |

### ៣-ការងារផែនការ និង ស្ថិតិ

ការិយាល័យ បានបូកសរុបរបាយការណ៍វឌ្ឍនភាពប្រចាំខែ មករា ឆ្នាំ ២០១៥។

### ៤-ការងារអធិការកិច្ច និង សវនកម្ម (គ្មានសកម្មភាព)

### ៥-ការងារទំនាក់ទំនងសាធារណៈ និង កិច្ចប្រជុំផ្សេងៗ

-លោក **មុំ ថៃម** ប្រធានមន្ទីរបានចូលរួមគ្រប់សកម្មភាពសង្គមនៅថ្នាក់ខេត្តបានចំនួន ១៣ លើក។

-លោក **តាន់ វាសនា** អនុប្រធានមន្ទីរបានចូលរួមគ្រប់សកម្មភាពសង្គមថ្នាក់ខេត្តបាន ០៥ លើក។

-លោក **សេង ជាសុខ** អនុប្រធានមន្ទីរបានចូលរួមគ្រប់សកម្មភាពសង្គមថ្នាក់ខេត្តបាន ៨ លើក។

## II. សកម្មភាពតាមវិស័យ

**១-ការងារផ្លូវជនបទ**( ថវិកាកម្មវិធី)

-លោក **សេង ជាសុខ** អនុប្រធានមន្ទីរ និង លោក **ម៉ាក់ មុន្នា** ប្រធានការិយាល័យផ្លូវលំជនបទនៅថ្ងៃទី ០៨ ខែមករា ២០១៥ បានចូលរួមជាមួយគណៈកម្មាធិការចម្រុះដឹកនាំដោយ **ឯកឧត្តម ហួន វ៉ាន់និត** អភិបាលរងខេត្ត ចុះត្រួតពិនិត្យក្រុមហ៊ុនចំការកៅស៊ូ CRCK ឈូសឆាយប៉ះពាល់ដីសហគមន៍ក្នុងឃុំដងកាំបិទ ស្រុកសណ្តាន់។

**២-ការងារផ្គត់ផ្គង់ទឹកស្អាតជនបទ** (ថវិកាកម្មវិធី) (គ្មានសកម្មភាព)

**៣-ការងារសុខភាពអនាម័យជនបទ**

-ចុះប្រមូលទិន្នន័យអ្នកជំងឺអេដ្ឋដែលចូលសម្រាកក្នុងមន្ទីរពេទ្យខេត្ត និងនៅសហគមន៍ ២ ថ្ងៃ។

**៤-ការងារអភិវឌ្ឍន៍សហគមន៍** (ថវិកាកម្មវិធី)

-បានលើកផែនការបណ្តុះបណ្តាលស្តីពី ការបញ្ជ្រាបការគ្រប់គ្រងគ្រោះមហន្តរាយដាក់ចូលក្នុងផែនការអភិវឌ្ឍន៍ ជូននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ចំនួន ៣ វគ្គ នៅឃុំកំពង់ស្វាយ ឃុំឈូក និងក្លែង។

**៥-ការងារបណ្តុះបណ្តាល និងស្រាវជ្រាវ**

សកម្មភាពអភិវឌ្ឍន៍ធនធានមនុស្សក្នុងប្រទេស

| ល.រ | ប្រភេទវគ្គ | | | ឈ្មោះមន្ត្រីចូលរួម | ខ្លឹមសារវគ្គ | រយៈពេល | ចំនួនថ្ងៃ | ទីកន្លែង | អ្នកគាំទ្រ |
|---|---|---|---|---|---|---|---|---|---|
| | ប | ស | ទ | | | | | | |
| ១ | | ស | | 1-លោក ស៊ីន វុទ្ធា | បូកសរុបលទ្ធផលឆ្នាំ ២០១៤ និងលើកកម្ពស់ផែនការឆ្នាំ ២០១៥ | 12-15/01/15 | 04 | បាត់ដំបង | Unicef |
| ២ | ប | | | 1-លោក ប្រាក់ មុត | CLTS | 13-21/01/15 | 09 | កំពង់ធំ | Plan International |
| | | | | | | | | | |

**៦-ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ** (គ្មានសកម្មភាព)

**៧-ការងារជនជាតិដើមភាគតិច** (គ្មានសកម្មភាព)

**៨-ការងារ** Gender÷ (គ្មានសកម្មភាព)

**៩-អង្គការក្នុង និង ក្រៅរដ្ឋាភិបាលក្រោមកិច្ចសហការជាមួយមន្ទីរ**

៩.១.អង្គការ iDE (គ្មានរបាយការណ៍)

៩.២.អង្គការស្អាតកម្ពុជា ÷ស្រុកបារាយណ៍ និងស្រុកសន្ទុក (គ្មានរបាយការណ៍)

៩.៣.អង្គការ CARITAS ÷ (គ្មានរបាយការណ៍)

៩.៤.**អង្គការ សកម្មភាពដើម្បីអភិវឌ្ឍន៍ (AFD)** (គ្មានរបាយការណ៍)

៩.៥. CWS (គ្មានរបាយការណ៍)

៩.៦. **អង្គការ Moslim Aid** (គ្មានរបាយការណ៍)

៩.៧. WVC ÷ បានសហការជាមួយមន្ត្រីមន្ទីរ ទទួលបានលទ្ធផលដូចខាងក្រោម÷

-បានចុះពិនិត្យសិក្សាទីតាំងអណ្តូងនៅឃុំចំណារលើសម្រាប់សាងសង់អណ្តូងថ្មីចំនួន ១៥ អណ្តូង ស្ថិតភូមិក្អិនចំនួន ៥ ភូមិ ល្អុងចំនួន ៤ ភូមិ ត្រពាំងជ័រចំនួន ៤ ភូមិគរ ចំនួន ២ ភូមិផ្តោច ចំនួន ១ កាលពីនៅថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៥។

-ចុះពិនិត្យ សិក្សាទីតាំងនៅឃុំបន្ទាយស្ទោង សម្រាប់សាងសង់អណ្តូងថ្មីចំនួន ៩ អណ្តូង ស្ថិតភូមិឈើទាលចំនួន ១ តាម៉ឺចំនួន ២ បវែងចំនួន ២ រលួសចំនួន ២ ដូនប៉ុកចំនួន ២ និងមណ្ឌលសុខភាពបន្ទាយស្ទោង ចំនួន ១ កាលពីនៅថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០១៤ ។

-ចុះពិនិត្យសិក្សាទីតាំងនៅឃុំបន្ទាយស្ទោង សម្រាប់សាងសង់អណ្តូងថ្មីចំនួន ៦ អណ្តូងស្ថិតភូមិបុស្សតាឯក (សាលាបុស្សតាឯក) ចំនួន ១ និងភូមិទំពេចចំនួន ៥ កាលពីនៅថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០១៤ ។

-ចុះពិនិត្យ សិក្សាទីតាំងនៅឃុំបន្ទាយស្ទោង សម្រាប់សាងសង់អណ្តូងថ្មីចំនួន ៧ អណ្តូង ស្ថិតភូមិព្រហ៊ូតចំនួន ៧ កាលពីនៅថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០១៥។

-ចុះពិនិត្យ សិក្សាទីតាំងនៅឃុំបន្ទាយស្ទោង សម្រាប់សាងសង់អណ្តូងថ្មីចំនួន ៦ អណ្តូង ស្ថិតភូមិក្រយាត្បូងចំនួន ១ (សាលាអនុវិទ្យាល័យ វិទ្យាល័យ) និង ភូមិសង្ឃាតចំនួន៥ កាលពីនៅថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០១៥ ។

-ចុះពិនិត្យ សិក្សាទីតាំងនៅឃុំបន្ទាយស្ទោង សម្រាប់សាងសង់អណ្តូងថ្មីចំនួន ១៥ អណ្តូង ស្ថិតភូមិគាន្ទាក់ចំនួន៨ និងភូមិត្រពាំងព្រីងចំនួន ៧ កាលពីនៅថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៥ ។

-បានចុះរកទីតាំងជីកអណ្តូងចំនួន ៤ អណ្តូង តាមសាលាបឋមសិក្សារស្មីអង្គាញ់ ភូមិអូររំចេក សាលាបឋមសិក្សាដូនល្អ ភូមិដូនល្អ សាលាបឋមសិក្សាប្រដិត ភូមិប្រដិត និងសាលាបឋមសិក្សាត្រាចជ្រុំ ភូមិត្រាចជុំដែលស្ថិតនៅ ឃុំសំព្រោច ស្រុកស្ទោង ខេត្តកំពង់ធំថ្ងៃទី ០៨ ខែ មករា ឆ្នាំ២០១៥ ។

-បានចុះផ្សព្វផ្សាយស្តីពីការលើកកម្ពស់អនាម័យតាមសាលាបឋមសិក្សា(HP) នៅស្ទោងមានសិស្សានុសិស្សចូលសរុប ៥២៣ នាក់/ស្រី ២៩៩ នាក់ ឃុំចំណាក្រោមចំនួន ៦ សាលា ។និង នៅស្រុកកំពង់ស្វាយមានសិស្សានុសិស្សចូលរួមសរុប ១៦១៧ នាក់/ស្រី ៧៨១ នាក់ ចំនួន ៥ សាលាបឋមសិក្សា។

-បានចុះបំផុសស្តីពីសហគមន៍ដឹកនាំអនុវត្តអនាម័យ (CLTS) នៅកំពង់ស្វាយ ភូមិជ័យ ឃុំសាន់គរ អ្នកចូលរួមសរុប ១១០ នាក់/ស្រី ៦៦ នាក់ ។

-បានចុះប្រជុំឆ្លុះបញ្ចាំងស្តីពីសហគមន៍ដឹកនាំអនុវត្តអនាម័យ (CLTS) នៅការិយាល័យ អង្គការទស្សនៈពិភពលោក នៅស្រុកកំពង់ស្វាយ អ្នកចូលរួមសរុប ២៦ នាក់/ស្រី ១៩ នាក់ (ឃុំត្បែង គឺភូមិត្រាច ឃុំសាន់គរ គឺភូមិបល្ល័ង្គ ភូមិតាំងក្រូច និងភូមិជ័យ) ។

-បានចុះផ្សព្វផ្សាយពីការលាងសំអាតដៃជាមួយសាប៊ូនៅស្រុក ប្រាសាទសំបូរបានចំនួន ៦ លើក មានអ្នកចូលរួមសរុប ៧៤៦ នាក់ស្រី ៣៤៦ នាក់។

**៩.៨. អង្គការ ពន្លឺអភិវឌ្ឍន៍ (APA)** (គ្មានរបាយការណ៍)

**៩.៩. អង្គការ ស្រែខ្មែរ ÷** (គ្មានរបាយការណ៍)

៩.១០.**អង្គការ** ADRA (គ្មានរបាយការណ៍)

**១០-កម្មវិធី និង គម្រោង**

**១០.១-គម្រោងផ្គត់ផ្គង់ទឹកនិងអនាម័យជនបទទី ២** (RWSSSP-2) (មន្ត្រីចំនួន ១០ នាក់)

-បានចុះបណ្តុះបណ្តាលអំពីការស្រង់ និងប្រមូលទិន្នន័យគម្រោងនៅឃុំ មានរិទ្ធ ដល់ VDC, CC, WSUG ដែលមានអ្នកចូលរួមសរុប ១៣៩ នាក់ ស្រី ៧៤ នាក់។

-ឃុំ មានជ័យ ស្រុក សណ្តាន់ចំនួន ១២០៣ បង្គន់ បានផ្តល់សម្ភារបង្គន់អនាម័យជូនសហគមន៍បាន ១០០% សហគមន៍ចូលរួមសាងសង់បានចំនួន ៩៧៦ បង្គន់។

-ឃុំ មានរិទ្ធ ស្រុក សណ្តាន់ ចំនួន ១១២៩ បង្គន់ បានផ្តល់សម្ភារបង្គន់អនាម័យជូនសហគមន៍ បាន១០០% សហគមន៍ចូលរួមសាងសង់បានចំនួន ៧០៧ បង្គន់។

-មន្ត្រីគម្រោងចំនួន ០៤ នាក់បានចូលរួមជាមួយមន្ត្រីជំនាញអង្គភាពគ្រប់គ្រងគម្រោងដឹកនាំ ដោយលោក ចេង ដូរ៉ាន់ បើកវគ្គបណ្តុះបណ្តាលស្តីពី វិធីសាស្ត្រសាងសង់ ជួសជុលបង្គន់លិចទឹក នៅ ឃុំ មានជ័យ ស្រុក សណ្តាន់ មានអ្នកចូលរួម ១៦ នាក់ ស្រី ៤ នាក់ (១៤/០១/១៥)។

**១០.២-គម្រោងផ្លូវក្រាលកៅស៊ូ** (RRIP-2) (មន្ត្រីចំនួន០៤នាក់) (គ្មានសកម្មភាព)

**១០.៣-កម្មវិធី** WFP (**ផ្លូវជីស**)(មន្ត្រីចំនួន០៤នាក់)

ចុះសិក្សាគម្រោងបានចំនួន២៩គម្រោង ក្នុងនោះ÷

-ផ្លូវជួសជុល២០គម្រោងប្រវែង ២០ គម គ្រោងស្បៀង ២៩៧ តោន។

-ផ្លូវសង់ថ្មី ៥ គម្រោង ប្រវែង ៥ គម គ្រោងស្បៀង ៦៥ តោន។

-ជួសជុលទំនប់១ គម្រោងប្រវែង ១គម គ្រោងស្បៀង ១៤ តោន។

-ទំនប់ថ្មី ៣ គម្រោងប្រវែង ៣ គម គ្រោងស្បៀង ៣៩ តោន។

**១០.៤-គម្រោងអភិវឌ្ឍន៍ជនបទតំបន់ទំនាបបឹងទន្លេសាប** (TSLRDP) (មន្ត្រីចំនួន ០៥ នាក់) (គ្មានសកម្មភាព)

**១០.៥-គម្រោង** ( RIP-III)(មន្ត្រីចំនួន ០៤ នាក់) (គ្មានសកម្មភាព)

**១០.៦-កម្មវិធី ទឹកស្អាត និង អនាម័យ** ( UNICEF) (មន្ត្រីចំនួន ៤ នាក់)

-បានចុះប្រជុំប្រចាំត្រីមាសថ្នាក់ឃុំ ឆ្លុះបញ្ចាំងការអនុវត្តកម្មវិធី CLTS៤ ឃុំលើ ២០ ភូមិ នៅស្រុកស្ទោង ប្រាសាទសំបូរ សន្ទុក ដោយមានអ្នកចូលរួមសរុប ១២៨ រូប ស្រី ៤៧ រូប ។

-បានចុះបើកវគ្គបណ្តុះបណ្តាល CLTS ដល់អ្នកសម្របសម្រួលអនាម័យភូមិ ចំនួន ១២ ភូមិថ្មីនៅស្រុក ស្ទោង និងស្រុកសន្ទុក មានអ្នកចូលរួមសរុប ១០៥ រូប ស្រី ៣៥ រូប។

**១០.៧-កម្មវិធីកំចាត់មីនខេត្ត** (MAPU ) (មន្ត្រីចំនួន ០១ នាក់) (គ្មានសកម្មភាព)

**១០.៨-គម្រោង** (LASED) (មន្ត្រីចំនួន ០២ នាក់) (គ្មានសកម្មភាព)

**១០.៩-គម្រោងស្បៀងបន្ទាន់** (Cash for Work)(មន្ត្រីចំនួន ០៤ នាក់)

III.**ទិសដៅបន្ត**

-នឹងសាងសង់ផ្លូវជនបទក្រាលកៅស៊ូ DBST ជំហានទី ២ ប្រមាណជា ៤៩ គ.ម ក្នុងនោះគឺ ÷

.ផ្លូវពីទ្រា ដល់ សាគ្រាម ប្រវែង ៤៩ គម ស្រុក ស្ទោង និងប្រាសាទបល្ល័ង្គ (ផ្លូវតាឃុំ)។

-គម្រោង RIP-III គ្រោងរៀបចំដេញថ្លៃផ្លូវជួសជុលចំនួន ៥ ខ្សែ ប្រវែង ៤១,២៤ គ.ម ក្នុងនោះ÷

.ទួលរកា ដល់ លឿក ប្រវែង ៨,៣ គ.ម ស្រុក បារាយណ៍ ។

.ទំនប់ ដល់ បឹង ប្រវែង ៨,២ គ.ម ស្រុក ប្រាសាទសំបូរ។

.បឹង ដល់ គោល ប្រវែង ៦,៩ គ.ម ស្រុក ប្រាសាទសំបូរ។

.ព្រៃក្ដី ដល់ តាំងស្ទោង ប្រវែង ៤,០៨ គ.ម ស្រុក ប្រាសាទសំបូរ។

.ថ្មី ដល់ ទឹកអណ្ដូង ប្រវែង ១៣,៧៦ គ.ម ស្រុក ប្រាសាទសំបូរ។

- ថែទាំផ្លូវជាលក្ខណៈខួបផ្លូវក្រាលគ្រួសក្រហម ចំនួន ០៣ ខ្សែ ប្រវែង ១៥,០០ គ.ម ស្ថិតក្នុងឃុំត្រពាំងប្ញស្សី ឃុំជ័យ ស្រុកកំពង់ស្វាយ និងឃុំចុងដូង ស្រុកបារាយណ៍ (គម្រោង TSLRDP) ។

-អង្គការ ADRA គ្រោង ២០១៥ នឹងផ្ដល់បង្គន់អនាម័យចំនួន ២០០ បង្គន់ និងផ្ដល់ធុងចម្រោះទឹកស្អាត៤៦០ ធុង នៅស្រុក បារាយណ៍ និង សន្ទុក។

## IV.**ផលវិបាក**

-ការអនុវត្តកម្មវិធីលទ្ធកម្មមានការយឺតយ៉ាវ។

-ប្រជាពលរដ្ឋជាប់រវល់ធ្វើស្រែចំការពុំបានចូលរួមជាមួយគម្រោងគ្រប់គ្នាទេ (RWSSSP2)។

-សហគមន៍ដែលទទួលបានសម្ភារៈ បង្គន់ដល់ផ្ទះហើយខ្វះការចូលរួមសាងសង់ (RWSSSP2)។

-អាជ្ញាធរនៅតាមតំបន់មួយចំនួនពុំបានយកចិត្តទុកដាក់ចំពោះគ.អ.ភ។

-គ.អ.ភ មួយចំនួនធ្វើ ចំណាកស្រុកដោយជីវភាពខ្វះខាត។

## V. **សំណូមពរ**

-រិះរកមធ្យោបាយណាដើម្បីឲ្យសហគមន៍ចូលរួមសាងសង់ និងទិញបង្គន់អនាម័យយកទៅប្រើប្រាស់។

-ស្នើសុំថវិកាទៅតាមផែនការសម្រាប់ឆ្នាំ ២០១៥ ឲ្យបានទាន់ពេលវេលា។

-គួរមានប្រាក់ឧបត្ថម្ភដល់សមាជិក គ.អ.ភ។

-សូមឲ្យនាយកដ្ឋានសេដ្ឋកិច្ចជនបទផ្ដល់ថវិកាដល់មន្ទីរសម្រាប់អនុវត្តឥណទានជនបទ។

ប្រធានមន្ទីរ